ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......០០១......សហវ.កបអ

# សេចក្តីណែនាំអនុវត្ត
# ស្តីពី
# កាតព្វកិច្ច និងវិធីសាស្ត្រផ្តល់ទិន្នន័យអ្នកដំណើរតាមផ្លូវអាកាស

អនុលោមតាមបញ្ញត្តិប្រកាសអន្តរក្រសួងលេខ ៥៥៤ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ស្តីពីការដាក់ឱ្យដំណើរការប្រើប្រាស់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស ក្រុមការងារអន្តរក្រសួងអនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស (**ក.ប.អ.**) សូមធ្វើការណែនាំបណ្តោះអាសន្នអំពីកាតព្វកិច្ចនិងវិធីសាស្ត្រមួយចំនួនដល់បណ្តាក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្មដែលមានប្រតិបត្តិការហោះហើរជាអន្តរជាតិចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រតិបត្តិក្នុងដំណាក់កាលអនុវត្តសាកល្បង លើការប្រើប្រាស់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស ដូចខាងក្រោម÷

## I- កាតព្វកិច្ចផ្តល់ទិន្នន័យអ្នកដំណើរតាមផ្លូវអាកាស

១. ត្រូវផ្តល់ទិន្នន័យព័ត៌មានអ្នកដំណើរជាមុន (Advance Passenger Information - API), កំណត់ត្រាឈ្មោះអ្នកដំណើរ (Passenger Name Record - PNR) និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតរបស់អ្នកដំណើរតាមផ្លូវអាកាស និងបុគ្គលិកក្នុងជើងយន្តហោះ នៅពេលធ្វើដំណើរចាកចេញ ឬ ចូលក្នុងព្រះរាជាណាចក្រកម្ពុជា។

២. ត្រូវធ្វើការតភ្ជាប់ប្រព័ន្ធរបស់ខ្លួនមកកាន់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស និងត្រូវ ធ្វើតេស្តដោយប្រើប្រាស់ទិន្នន័យសាកល្បង ដើម្បីធានាថាប្រព័ន្ធអាចផ្លាស់ប្តូរទិន្នន័យបាន ហើយទម្រង់ឯកសារដែលតម្រូវឱ្យប្រើប្រាស់ អាចទទួលស្គាល់ដោយប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស។

៣. ត្រូវបញ្ជូនទិន្នន័យព័ត៌មានអ្នកដំណើរជាមុន និងកំណត់ត្រាឈ្មោះអ្នកដំណើរ មកកាន់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ក្នុងទម្រង់ដែលបានកំណត់ និងតាមលំដាប់ពេលវេលា ដូចក្នុងសេចក្តីណែនាំ Cambodia API / PNR Operation Manual ភ្ជាប់ក្នុងឧបសម្ព័ន្ធមកជាមួយនេះ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## II- វិធីសាស្ត្រផ្តល់ទិន្នន័យអ្នកដំណើរតាមផ្លូវអាកាស

ទិន្នន័យព័ត៌មានអ្នកដំណើរជាមុន និងកំណត់ត្រាឈ្មោះអ្នកដំណើរ ត្រូវបញ្ជូនតាមរបៀបរុញ (Push Mode)។ ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្ម ដែលមានប្រតិបត្តិការហោះហើរជាអន្តរជាតិចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ត្រូវបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកផ្តល់សេវាកម្ម ដែលក្រុមហ៊ុនបានប្រើប្រាស់ក្នុងការបញ្ជូនទិន្នន័យប្រសិនបើមាន និងត្រូវបញ្ជាក់ពីពិធីសារបច្ចេកទេស (Technical Protocol) ដែលត្រូវប្រើសម្រាប់បញ្ជូនទិន្នន័យ។ ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស អាចអនុញ្ញាតឱ្យក្រុមហ៊ុនតភ្ជាប់ប្រព័ន្ធតាមតម្រូវការ ដោយប្រើប្រាស់វិធីសាស្ត្របញ្ជូនទិន្នន័យ និងទម្រង់ឯកសារដែលមានស្តង់ដារអន្តរជាតិ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការរៀបចំទិន្នន័យ ដូចខាងក្រោម÷

១. ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស អាចទទួលយកទិន្នន័យតាមវិធីសាស្ត្របញ្ជូនទិន្នន័យពីប្រព័ន្ធទៅប្រព័ន្ធ (System to System) មានដូចជា MQ Connector, Web Service, Sftp និង E-mail ជាដើម។

២. ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស អាចទទួលយកទិន្នន័យតាមទម្រង់ឯកសាររួមមាន÷ ICAO - PNRGOV ជំនាន់ 11.1 ឡើងទៅ សម្រាប់ទិន្នន័យកំណត់ត្រាឈ្មោះអ្នកដំណើរ និង UN/EDIFACT - PAXLST ជំនាន់ 02B ឡើងទៅ សម្រាប់ព័ត៌មានអ្នកដំណើរជាមុន។

## III- ការពិន័យ

ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្ម ដែលមានប្រតិបត្តិការហោះហើរជាអន្តរជាតិចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ដែលខកខានក្នុងការអនុវត្តតាមចំណុច I និងចំណុច II ខាងលើ ត្រូវរងការពិន័យរដ្ឋបាល និង/ឬទោសទណ្ឌផ្សេងទៀត តាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ទទួលបានសេចក្តីណែនាំជាបណ្តោះអាសន្ន សម្រាប់អនុវត្តក្នុងដំណាក់កាលសាកល្បងនេះ សូមបណ្តាក្រុមហ៊ុនអាកាសចរណ៍ពាក់ព័ន្ធដូចខាងលើ សហការអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ រហូតមានការណែនាំជាថ្មី។

ថ្ងៃ ចន្ទ ៣កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០២១

**ប្រធានក្រុមការងារអន្តរក្រសួង**

**អនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស**

**នួន ចំរើន**

**ចម្លងជូន÷**

- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល "ដើម្បីជូនជ្រាប"
- គ្រប់ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្ម "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ